00291596

**Declassified to Public**
**06 September 2012**

E28/1

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ: | ០០១/១៨-០៧-២០០៧-អវតក/អជសដ |
| ដាក់តម្កល់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| កាលបរិច្ឆេទដាក់ឯកសារ: | ២៤/០៣/២០០៩ |
| ភាគីអ្នកតម្កល់: | មេធាវីលោក កាំង ហ្គេកអ៊ាវ |
| ភាសាដើម: | ភាសាបារាំង |
| ប្រភេទឯកសារ: | សាធារណៈ |

**ចម្លើយតបរបស់ក្រុមមេធាវីការពារ នៅលើបញ្ជីឈ្មោះសាក្សី**
**និងឯកសារនានាដែលដាក់តម្កល់ដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១**

**អ្នកដាក់តម្កល់:**
**សហមេធាវី**
**កាំង ហ្គេកអ៊ាវ**
លោក **ការ សាវុត្ថ**
លោក François ROUX

**តម្កល់ជូន:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម **យ៉ា សុខន**
ចៅក្រម**Jean-Marc LAVERGNE**
ចៅក្រម **ធូ មណី**

**ចម្លងជូន:**
**សហព្រះរាជអាជ្ញា**
លោកស្រី **ជា លាង**
លោក **Robert PETIT**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
24 / 03 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
25 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**ចម្លងជូន:**
**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
មេធាវី **គង់ ពិសី**
មេធាវី **ហុង គឹមសួន**
មេធាវី **យុង ផានិត**
មេធាវី **គីម ម៉េងឃី**
មេធាវី **ម៉ុច សុវណ្ណារី**

Me Silke STUDZINSKY
Me Martine JACQUIN
Me Philippe CANNONE
មេធាវី **ទី ស្រីនណា**
Me Pierre Olivier SUR
Me Alain WERNER
Me Brianne McGONIGLE
Me Annie DELAHAIE
MeElizabethRABESANDRATANA
Me Karim KHAN

00291597



## គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I. ការលើកឡើងអំពីអង្គហេតុ និងកម្មវត្ថុនៃសំណើរសុំ

១. ក្រុមមេធាវីការពារក្តី បានទទួលរួចមកហើយនូវសេចក្តីជូនដំណឹងស្តីពីបញ្ជីឈ្មោះសាក្សីដែលដាក់តម្កល់ដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ជាភាសាខ្មែរ និងជាភាសាអង់គ្លេស កាលពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩។

២. ក្នុងអំឡុងពេលសវនាការបឋមកាលពីថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្រុមមេធាវីការពារបានប្រកាន់នូវជំហររបស់ខ្លួនក្នុងលក្ខណៈបឋមពាក់ព័ន្ធទៅនឹងសំណើរសុំដែលធ្វើឡើងដោយក្រុមមេធា-វីដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុម១ ដែលមានបំណងបញ្ចូលសាក្សីចំនួន ១នាក់ បន្ថែមទៀតទៅក្នុង "អង្គសវនាការដើម្បីធ្វើការសម្រេចសេចក្តី" [1]។

៣. ក្រុមមេធាវីការពារ បានគូសបញ្ជាក់រួចមកហើយថា ខ្លួនបានបដិសេធយ៉ាងដាច់ណាត់ទៅនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះអ្វីដែលភាគីនេះអាចស្នើអំពីការដាក់ទោស និងសូមបញ្ជាក់អំពីហេតុផលនៃការជំទាស់នេះយ៉ាងខ្លី។ ចំពោះចំណុចនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម៤ ក៏បានឯកភាពតាមមេធាវីការពារផងដែរ [2]។

៤. ក្នុងពេលសវនាការ អង្គជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះនឹងធ្វើការសម្រេចនាពេលក្រោយទៅលើបញ្ហាសាក្សីដែលមានរាយនាមក្នុងបញ្ជីឈ្មោះសាក្សីដែលផ្តល់ដោយមេធាវីដើមបណ្តឹងរដ្ឋ-ប្បវេណី ក្រុម ១។ [3]

---

[1] សូមពិនិត្យមើលរបាយការណ៍សវនាការថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដែលបានធ្វើជាសាធារណៈ ត្រង់ទំព័រ ៥ ដល់ ៧ (E1/4.1) សូមពិនិត្យមើលផងដែរនូវរបាយការណ៍សវនាការ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដែលធ្វើជាសម្ងាត់ ត្រង់ទំព័រ ៨ និង ៩ (E1/4.2) និងរបាយការណ៍សវនាការ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ សវនាការសាធារណៈ ទំព័រ ៥៤ (E1/3.1)។

[2] សូមពិនិត្យមើលរបាយការណ៍សវនាការថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដែលបានធ្វើជាសាធារណៈ ត្រង់ទំព័រ ៨ ដល់ ១០ (E1/4.1) និងសវនាការជាសម្ងាត់ ត្រង់ទំព័រ ១០ និង ១១ (E1/4.2)។

[3] សូមពិនិត្យមើលរបាយការណ៍សវនាការ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ សវនាការធ្វើឡើងជាសាធារណៈ ទំព័រទី៣ និង ២១ (E1/4.1)។

៥. កាលពីថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៩ ក្រុមមេធាវីការពារបានទទួលនូវសេចក្តីជូនដំណឹងស្តីពីបញ្ជីឈ្មោះសាក្សី និង ឯកសារនានាដែលដាក់តម្កល់ដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងក្រុម ១ ជាភាសាបារាំង។

៦. ដោយបានជ្រាបច្បាស់អំពីពាក្យសុំទាំងឡាយរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងក្រុម១ ក្រុមមេធាវីការពារសូមលើកឡើងនូវទឡ្ហីករណ៍ទាំងឡាយរបស់ខ្លួនដូចមានបង្ហាញជូនខាងក្រោម ពាក់ព័ន្ធទៅនឹងបញ្ជីឈ្មោះសាក្សី និងឯកសារនានារបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

## II. ទឡ្ហីករណ៍របស់មេធាវីការពារ

៧. មេធាវីការពារសូមបញ្ជាក់ហើយ បញ្ជាក់ទៀតថា ខ្លួនមិនបានប្រឆាំងទៅនឹងការដែលភាគី ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមយ៉ាងសកម្មទៅក្នុងដំណើរការនីតិវិធីនៃរឿងក្តីរបស់ **កាំង ហ្កេកអ៊ាវ** នោះទេ។

៨. ផ្ទុយទៅវិញ មេធាវីការពារសូមសំណូមពរអោយអង្គជំនុំជម្រះទាំងមូល មេត្តាកំណត់អំពីតួនាទីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះ ដោយធ្វើការពិចារណាផងដែរអំពីលក្ខណៈពិសេស និងព្រំដែននៃសិទ្ធិក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក [4] និងសូមពិនិត្យមើលពីការគោរពដល់សិទ្ធិរបស់ភាគីមេធាវីការពារផងដែរ ហើយជាពិសេសការគោរពសិទ្ធិក្នុងការទទួលបានការជំនុំជម្រះសេចក្តីមួយប្រកបដោយសមធម៌។

## ក. សិទ្ធិមានកំណត់ក្នុងការអនុវត្តបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក

៩. យោងលើវិធានច្បាប់របស់កម្ពុជាសម្រាប់អនុវត្តក្នុង អ.វ.ត.ក មេធាវីការពារយល់ឃើញថា៖
**- ទីមួយ** សហព្រះរាជអាជ្ញា និង ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់នូវពាក្យបណ្តឹងនៅចំពោះមុខ អ.វ.ត.ក ហើយដែលពាក្យបណ្តឹងរបស់ភាគីទាំងពីរនេះមានកម្មវត្ថុពីរផ្សេងពីគ្នា។ បណ្តឹងទាំងពីរ

---

[4] សូមពិនិត្យមើល " សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី" អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០០៩ (E2/5/3) កថាខណ្ឌ៨។

នោះមាន បណ្តឹងអាជ្ញា និងការការពារផលប្រយោជន៍សង្គមទាំងមូល ជាបណ្តឹងចម្បង និងបណ្តឹងរដ្ឋប្បវេណី និងការពារផលប្រយោជន៍បុគ្គលជាធំ ជាបណ្តឹងបន្ទាប់បន្សំ។ និង

- **ទីពីរ** បញ្ហាពាក់ព័ន្ធទៅនឹងការសម្រេចពីទោស គឺជាសមត្ថកិច្ចរបស់ម្ចាស់បណ្តឹងអាជ្ញា ពោល គឺជាសមត្ថកិច្ចផ្ទាល់របស់សហព្រះរាជអាជ្ញា។

១០. ហេតុដូចនេះ មេធាវីការពារសូមសន្និដ្ឋានថា នៅចំពោះមុខ អ.វ.ត.ក ភាគីដើមបណ្តឹងរដ្ឋប្បវេណី គ្មានសមត្ថកិច្ចក្នុងការស្នើសុំការដាក់ទោសឡើយ ហើយនិងមិនត្រូវបានអនុញ្ញាតឲ្យបញ្ចូលខ្លួនសាក្សីដើម្បីសម្រេចពីបញ្ហានេះឡើយ។

១១. ប្រការនេះ អនុលោមទៅតាមការវិភាគលើបទបញ្ញតិនានានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលសមស្របក្នុងករណីនេះ ហើយដែលចែងថា៖

i. ជនរងគ្រោះអាចអនុវត្តបានតែបណ្តឹងរដ្ឋប្បវេណីមួយប៉ុណ្ណោះ [5] ។ មានតែសហព្រះរាជអាជ្ញាមួយ ប៉ុណ្ណោះដែលជាម្ចាស់ និងជាអ្នកធ្វើបណ្តឹងអាជ្ញា [6]។

ii. បន្ទុកនៃភស្តុតាងត្រូវធ្លាក់ទៅលើសហព្រះរាជអាជ្ញា [7] ។

iii. មានតែសហព្រះរាជអាជ្ញាមួយគត់ ដែលមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល [8] ដែលសិទ្ធិនេះបានគ្របដណ្តប់សិទ្ធិក្នុងការសុំឱ្យមានការផ្តន្ទាទោសណាមួយទៅលើជនជាប់ចោទ និងស្នើសុំអំពីទំហំនៃការដាក់ទោសនោះផងដែរ។

iv. ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេច ដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍រដ្ឋប្បវេណីរបស់ខ្លួនបានឡើយ លើកលែងតែក្នុងករណីដែលមានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងរឿងនោះតែប៉ុណ្ណោះ [9]។

ត្រង់ចំណុចនេះបានសេចក្តីថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើបណ្តឹងសាទុក្ខអំពីការអនុវត្តទោសឡើយ ប្រសិនបើខ្លួនយល់ឃើញថាការអនុវត្តទោសនោះមិនសមស្របទៅនឹងអ្វីដែលខ្លួនចង់បាន។ មានតែ សហព្រះរាជអាជ្ញាមួយប៉ុណ្ណោះ ដែលមានសិទ្ធិទៅលើរឿងនេះ។

---

[5] វិធាន ២៣ នៃវិធានផ្ទៃក្នុងដែលមានចំណងជើងថា " បណ្តឹងរដ្ឋប្បវេណីរបស់គូរភាគី" ។

[6] វិធាន ៤៩ នៃវិធានផ្ទៃក្នុងដែលមានចំណងជើងថា " ការអនុវត្តបណ្តឹងអាជ្ញា" ។

[7] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[8] វិធាន ៩៤ (១) នៃវិធានផ្ទៃក្នុង។

[9] វិធាន ១០៥ (១) នៃវិធានផ្ទៃក្នុង។

១២. មេធាវីការពារយល់ឃើញថា វិធានផ្ទៃក្នុងនៃ អ.វ.ត.ក យោងទៅលើបទបញ្ញត្តិពិសេសរបស់ខ្លួន បានចែងអំពីវិធាននីតិវិធីដ៏សមស្របបំផុតពាក់ព័ន្ធដល់ការកំណត់អំពីតួនាទីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខ អ.វ.ត.ក។ ក៏ប៉ុន្តែ បើសិនជាអាចធ្វើទៅបាន អង្គជំនុំជម្រះសាលាដំបូងអាចយោងទៅលើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលក្រមនេះបានចែងនូវបទបញ្ញត្តិដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងបទបញ្ញត្តិដែលបានចែងដោយ វិធានផ្ទៃក្នុងនៃ អ.វ.ត.ក ពាក់ព័ន្ធទៅនឹងសិទ្ធិនិយាយស្តីរបស់គូភាគីក្នុងពេលជំនុំជម្រះ និងសិទ្ធិមានកំណត់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ទៅនឹងសាលក្រម[10] ហើយ និងបានកំណត់និយមន័យយ៉ាងច្បាស់លាស់ អំពីអ្វីទៅជាបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីក្នុងក្របខណ្ឌនៃរឿងក្តីព្រហ្មទណ្ឌ តាមច្បាប់របស់កម្ពុជា។ ក្រមនេះក៏បានចែងផងដែរ ក្នុងមាត្រា ២ របស់ខ្លួនដែលថា ៖ " បណ្តឹងអាជ្ញាមានគោលបំណង (...) ផ្តន្ទាទោស (...) តាមច្បាប់ដែលបានកំណត់" [11] និងតាមរយៈមាត្រា ៤ ដែលបានចែងថា " *បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។* "[12]

១៣. ម្យ៉ាងទៀត មេធាវីការពារយល់ឃើញថា ដោយសារ អ.វ.ត.ក ស្ថិតក្នុងប្រព័ន្ធតុលាការរបស់កម្ពុជា ដែលប្រព័ន្ធតុលាការនេះមានមូលដ្ឋានរបស់ខ្លួនផ្អែកលើប្រព័ន្ធច្បាប់របស់បារាំង ពាក់ព័ន្ធដល់នីតិវិធីព្រហ្មទណ្ឌ វាជាការចាំបាច់មួយដែលអង្គជំនុំជម្រះសាលាដំបូងគួរពិនិត្យមើលអំពីការអនុវត្តជាក់ស្តែងពាក់ព័ន្ធដល់តួនាទីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខតុលាការព្រហ្មទណ្ឌបារាំង។ ជាក់ស្តែងដូចដែលមេធាវីការពារលោក **កាំង** ក៏ដូចជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម

---

[10] មាត្រា ៣៣៥, ៣៣៦, ៣៧៥ និង ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

[11] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា:

*"បណ្តឹងអាជ្ញានិងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងពីរផ្សេងពីគ្នា។*

*បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។*

*បណ្តឹងរដ្ឋប្បវេណីមានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាត ដែលបណ្តាលមកអំពីអំពើល្មើសដល់គូរភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។"*

[12] មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា:

*"បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផល ប្រយោជន៍ទូទៅដោយអយ្យការ។*

*អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ"។*

៤ បានលើកឡើងក្នុងអង្គសវនាការបឋមកាលពីថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ថា នៅប្រទេសបារាំងចំពោះរឿងក្តីព្រហ្មទណ្ឌ ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិសុំឱ្យមានការអនុវត្តទោសឡើយ តួនាទីនេះត្រូវបានប្រគល់ផ្តាច់មុខទៅឱ្យអយ្យការ [13]។

១៤. ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីយល់ឃើញថា ច្បាប់របស់កម្ពុជាមានបទបញ្ញត្តិនានាដែលមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ ស្តីអំពីតួនាទីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ គេមិនគួរដាក់ឱ្យអនុវត្តនូវរាល់បទបញ្ញត្តិនៃវិធាន២ នៃវិធានផ្ទៃក្នុងរបស់ អវតក និងយោងលើវិធានទាំងឡាយនៃនីតិវិធីដែលបានបង្កើតឡើងនៅកំរិតអន្តរជាតិ ហើយកាន់តែមិនគួរថែមទៀតដោយហេតុថា នៅក្នុងយុត្តាធិការអន្តរជាតិដទៃទៀត គេមិនឃើញមានភាគីដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

## ខ. សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជម្រះក្តីប្រកបដោយសមធម៌

១៥. ក្រុមមេធាវីការពារក្តីគូសបញ្ជាក់ថា ការបង្ហាញខ្លួនរបស់សាក្សីកោះហៅតាមសំណើរបស់មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីដោះស្រាយបញ្ហាកំណត់ទោសនោះគឺមិនត្រឹមតែផ្ទុយទៅនឹងវិធាន និងស្មារតីរបស់នីតិកម្ពុជាដែលអនុវត្តនៅ អ.វ.ត.ក ទេ ប៉ុន្តែថែមទាំងរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជម្រះក្តីប្រកបដោយសមធម៌ ដែលជាសិទ្ធិការពារដោយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ (Pacte international relatif aux droits civils et politiques - PIDCP) ថែមទៀតផង [14]។

១៦. ដូច្នេះ ប្រសិនណាអង្គជំនុំជម្រះសាលាដំបូងប្រគល់ដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិតម្រូវឱ្យមានការស្តាប់សាក្សីចំពោះបញ្ហាកំណត់ទោស ការធ្វើបែបនេះបានសេចក្តីថាអង្គជំនុំជម្រះសាលាដំបូងផ្តល់សិទ្ធិដល់ពួកគេដើម្បីសម្រេចពីការដាក់ទោស ព្រមទាំងសិទ្ធិបញ្ចេញទឡ្ហីករណ៍នៅត្រង់បញ្ហានេះដូច្នោះដែរ។ តុល្យភាពនៃមធ្យោបាយការពារខ្លួនរបស់គូរភាគីក្នុងរឿងក្តីនេះនឹងត្រូវបានរំលោភបំពាន ដោយហេតុថាក្រុមមេធាវីការពារក្តីត្រូវប្រឈមមុខឆ្លើយមិនត្រឹមតែទឡ្ហីករណ៍

---

[13] សូមមើល របាយការណ៍សវនាការថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ - សវនាការសាធារណៈ ទំព័រទី៥ ដល់ទី៧ និង ទំព័រទី៨ ដល់ទី១០ (E1/4.1) និង សវនាការជាអសាធារណៈ ទំព័រទី៨ ដល់ទី១១ (E1/4.2)។

[14] សូមមើលផងដែរវិធាន២១ (១)(ក) នៃវិធានផ្ទៃក្នុងរបស់ អវតក ព្រមទាំងមាត្រា៣៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អវតក។

ទាក់ទងនឹងបញ្ហាទោសដែលលើកឡើងដោយការិយាល័យសហព្រះរាជអាជ្ញាប៉ុណ្ណោះទេ តែថែមទាំងតតាំងទៅនឹងទឡ្ហីករណ៍ដែលលើកឡើងដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលដើរតួនាទីដូចជាសហព្រះរាជអាជ្ញាថែមទៀតផង។

១៧. ម្យ៉ាងវិញទៀត ការបង្ហាញខ្លួនរបស់សាក្សីដែលស្នើសុំដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី និងការបង្ហាញទឡ្ហីករណ៍អំពីទោសដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី និងធ្វើឱ្យការជជែកដេញដោលកាន់តែវែងអន្លាយទៅ ហើយប្រការនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការវិនិច្ឆ័យទោសក្នុងរយៈពេលមួយសមស្របមួយ។

## III. សំណើ

១៨. វិធាន ៨០ (២) នៃវិធានផ្ទៃក្នុងរបស់ អវតក ចែងអំពីលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបដិសេធការបង្ហាញខ្លួនរបស់សាក្សី ឬអ្នកជំនាញបើសិនជា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស្តាប់ចម្លើយជននេះមិនចាំបាច់សម្រាប់ការវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវនោះទេ។

១៩. ក្រុមមេធាវីការពារក្តីយល់ឃើញថា ដោយយោងទៅលើរាល់ហេតុផលទាំងឡាយដែលបានលើកឡើងខាងលើ ការយល់ព្រមឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីនៃក្រុមទី១ នូវសិទ្ធិឱ្យមានការបង្ហាញខ្លួនរបស់លោកសាស្ត្រាចារ្យ Christophe Staker និងលោកស្រីបណ្ឌិត Phuong Pham ក្នុងនាមជាសាក្សី ដើម្បីដោះស្រាយបញ្ហាកំណត់ទោស គឺមិនសមស្របសម្រាប់ការវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវនោះឡើយ។

២០. មេធាវីការពារសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាច្រានចោលការសុំបញ្ចូលសាក្សីចំនួនពីរនាក់នោះ ពីសំណាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

## ហេតុដូច្នេះ

២១. ដោយយោងទៅលើរាល់ហេតុផលទាំងនេះ និងដោយអនុវត្តវិធាន៨០ (២) នៃវិធានផ្ទៃក្នុងរបស់អវតក និងមាត្រា១៤ នៃ PIDCP ក្រុមមេធាវីការពារក្តីស្នើសុំឱ្យ អង្គជំនុំជម្រះសាលាដំបូង៖

- មេត្តាប្រកាស និងសម្រេចថា គឺមានតែអយ្យការប៉ុណ្ណោះ ជាអ្នកដោះស្រាយបញ្ហាទាក់ទងនឹងការកំណត់ទោសនៅក្នុងរឿងក្តី មិនមែនជាសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ
- បដិសេធចោលសំណើសុំបង្ហាញខ្លួនលោកសាស្ត្រាចារ្យ Christophe Staker និងលោកស្រីបណ្ឌិត Phuong Pham ដែលមានឈ្មោះនៅក្នុងបញ្ជីសាក្សីរបស់សហមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៃក្រុម ១។

E28/1

[០០១/១៨-០៧-២០០៧-អវតក/អជសង]

**សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**

| | | |
|---|---|---|
| មេធាវីម្នាក់ក្នុងចំណោមមេធាវីទាំងពីរ<br><br>មេធាវី **ការ សាវុត្ថ**<br><br><br>មេធាវី **François ROUX** | ភ្នំពេញ | |